**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ៖** ១០ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី រៀបចំ និងការ ប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការ បង្កើតក្រសួងរៀបចំដែនដី និងនគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១១ ខែមករា ឆ្នាំ២០០២

## សំរេច

**មាត្រា ១.-**

កំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មមួយនៅក្នុងភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ឈ្មោះថា តំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង

**មាត្រា ២.-**

តំបន់កឧស្សាហកម្មនាងកុក ខេត្តកោះកុង មានទំហំ ៣៣៦,២៤ ហិកតា។ តំបន់ឧស្សាហកម្មនេះស្ថិតនៅក្នុងខ្សែបន្ទាត់ព្រំ A, B, C, D, E, F, G, H, I, J, K, L, M, N, O, P ហើយនិយាមការនៃចំណុចខ្សែបន្ទាត់ព្រំដីនេះ និងប្លង់ទីតាំងដីមាននៅក្នុងឧបសម្ព័ន្ធ ដែលជាចំណែកភ្ជាប់ក្នុងអនុក្រឹត្យនេះ។

**មាត្រា ៣.-**

ផ្ទៃដីទាំងអស់ដែលនៅក្នុងបរិវេណតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុងដូចបានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិរបស់រដ្ឋ ហើយបែបបទនៃការរៀបចំ និងនីតិវិធីនៃការគ្រប់គ្រងតំបន់ឧស្សាហកម្មនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៤.-**

រាល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ព្រមទាំងឯកសារទាំងឡាយណាដែលពាក់ព័ន្ធនឹងសិទ្ធិលើដីធ្លី ដែលស្ថិតក្នុងតំបន់ឧស្សាហកម្ម ភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះអោយមាន ប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**